# ៩ វិច្ឆិកា ២០១៩ ?

ជាថ្ងៃដែលលោក សម រង្ស៊ី ប្រកាសជាឧឡារិកថានឹងវិលត្រឡប់ចូលស្រុកខ្មែរវិញ។ គាត់សង្ឃឹមថា ថ្ងៃនោះនឹងអាចមានដំណោះស្រាយនយោបាយ តាមឧបាស្រ័យអនុគ្រោះទោសពីសំណាក់ព្រះមហាក្សត្រដល់រូបគាត់ តាមការស្នើពី ហ៊ុន សែន ព្រោះវាជាទម្លាប់បុណ្យជាតិ។ ចុះបើព្រឹត្តិការណ៍នេះ វានឹងអាចកើតឡើងពិតគឺច្បាស់ជាមានដំណោះស្រាយជាថ្មី រវាង រង្ស៊ី នឹង សែន ក្នុងនោះ គឺអ្វីៗដែល រង្ស៊ី លើកឡើងថាជាបញ្ហាស្លាប់រស់របស់ជាតិដែលរបបភ្នំពេញជាអ្នកធ្វើ វានឹងអាច នរះនេះ បំភ្លេចចោលជាថ្មី រួមទាំង ការដោះលែង គឹម សុខា និង ដំណើរការឡើងវិញនៃគណបក្សសង្គ្រោះជាតិ ដើម្បីធ្វើសម្បទាន ជាមួយ ហ៊ុន សែន។ យើងឃើញថា វិលចុះវិលឡើង រង្ស៊ី ត្រឡប់មករក ហ៊ុន សែនដដែល។ តែ រង្ស៊ី ភ្លេចគិតថា ទំនាស់ គាត់ នឹង សែន វាមានធម្មជាតិ ជាទំនាស់បុគ្គលឯកជន នៅត្រង់ចំណុច ដែលគាត់ចោទប្រកាន់ គ្មានភ័ស្តុតាងជាក់ស្តែងថា ហ៊ុន សែន ជាអ្នកនៅពីក្រោយគ្រោះថ្នាក់ដល់ស្លាប់ ហុក ឡុងឌី ដែលមានកូនប្រុស ជាកូនប្រសារ ហ៊ុន សែន។ ទង្វើនេះ វាឈឺណាស់ក្នុងចិត្តសែន។ ជម្រើសថ្ងៃទី៩ វិច្ឆិកា វាបង្ហាញរួចហើយថា រង្ស៊ី មិនយកប្រជាពលរដ្ឋខ្មែរជាគម្លាស់ នៃយុទ្ធសាស្រ្តនយោបាយរបស់គាត់នោះឡើយ។ ដូច្នេះ បើគ្មានរាជអនុគ្រោះទោស គឺ គាត់មិនវិលត្រឡប់ចូលស្រុកខ្មែរវិញទេ ព្រោះគាត់ជាមនុស្សជា មិនយកទុក្ខដាក់ខ្លួន ដូច សែន ជាមនុស្សឆ្កួត៕